# សុន្ទរកថាស្វាគមន៍របស់នាយកចាត់ការទូទៅក្រុមហ៊ុន TMCC ក្រោមប្រធានបទ ទស្សនាទានចែករំលែកបង្គោលអង់តែនប្រើប្រាស់រួមគ្នា

---

សូមគោរពឯកឧត្តមរដ្ឋមន្ត្រី ភ្ញៀវកិត្តិយស លោក-លោកស្រីជាវាគ្មិន ជំនាញការ សិក្ខាកាម លោក-លោកស្រីទាំងអស់ ជាទីគោរពរាប់អាន!

តាងនាមឱ្យក្រុមហ៊ុន TMCC និងតាងនាមឱ្យខ្លួនខ្ញុំផ្ទាល់ ខ្ញុំមានកិត្តិយសយ៉ាងក្រៃលែងដែលមានវត្តមាន នៅក្នុងអង្គសិក្ខាសាលានាថ្ងៃនេះ ជាមួយឯកឧត្តម លោកជំទាវ អស់លោក-លោកស្រីទាំងអស់ ហើយនឹងសូមថ្លែងអំណរគុណចំពោះអង្គសិក្ខាសាលា និងប្រតិភូទាំងអស់ដែលមានវត្តមាននៅក្នុងសិក្ខាសាលានេះ ជាពិសេស ឯកឧត្តម **សូរ ឃុន** រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍នៃព្រះរាជាណាចក្រកម្ពុជា ឯកឧត្តម លោកជំទាវ អស់លោក-លោកស្រីជាវាគ្មិន សមាជិក-សមាជិកានៃបណ្តាញសារព័ត៌មាន លោក-លោកស្រី អ្នកនាងកញ្ញាជាទីគោរពរាប់អាន។

ទន្ទឹមនឹងនេះដែរ ខ្ញុំសូមអរគុណចំពោះឯកឧត្តមរដ្ឋមន្ត្រីផងដែរ ដែលបានផ្តល់ឱកាស និង បង្កលទ្ធភាពឱ្យយើងបានជួបជុំគ្នានៅក្នុងសិក្ខា សាលានាពេលព្រឹកដ៏ស្រស់ស្រាយនេះ។

ឆ្លៀតក្នុងឱកាសនេះ ខ្ញុំសូមអនុញ្ញាតសំដែងការស្វាគមន៍ជូនចំពោះតំណាងមកពីក្រុមហ៊ុនបំរើសេវាទូរគមនាគមន៍ជំនាញការជាតិ និងអន្តរជាតិ ដែលនឹងឡើងថ្លែងនូវសេចក្តីរាយការណ៍ជូនដល់អង្គសិក្ខាសាលា និងសិក្ខាកាមទាំងអស់ដែលមានវត្តមាននៅក្នុងសិក្ខាសាលានានាព្រឹកនេះ។

កម្មវត្ថុជាចំបងនៃអង្គសិក្ខាសាលានេះគឺដើម្បីផ្តល់នូវឱកាសសំរាប់ធ្វើការឆ្លុះបញ្ចាំង ពិភាក្សា និងសិក្សាវិភាគអំពីបទពិសោធន៍របស់ប្រទេសម៉ាឡេស៊ីទាក់ទងទៅនឹងទស្សនាទានចែករំលែកបង្គោលអង់តែនរួមគ្នា ដើម្បីទទួលបាននូវភាពជោគជ័យ។ ខ្ញុំសង្ឃឹមថានៅពេលបញ្ចប់អង្គសិក្ខាសាលានេះ ឯកឧត្តម លោកជំទាវ អស់លោក លោកស្រីនឹងអាចស្វែងយល់អំពីអត្ថប្រយោជន៍ ព្រមទាំង សហការស្រាវជ្រាវ និងអភិវឌ្ឍន៍កម្មវិធីនេះជាក់ជាមិនខាន។

ក្នុងស្មារតីនេះដែរ ខ្ញុំសូមថ្លែងអំណរគុណចំពោះក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍នៃព្រះរាជាណាចក្រកម្ពុជា ដែលបានផ្តល់ជូនយើងខ្ញុំនូវសិទ្ធិសម្បទានរយៈពេល ៣៥ ឆ្នាំ ក្នុងការតំឡើង និងលការថែទាំបង្គោលអង់តែនទូរគមនាគមន៍

ជាមួយនឹងការសាងសង់សម្ភារៈបរិក្ខាសំរាប់ជួលជាវ ដោយឈរលើមូលដ្ឋានចែករំលែករយៈពេលយូរអង្វែងមួយជាមួយនឹងបណ្ដាក្រុមហ៊ុនទូរគមនាគមន៍នានានៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

ដោយមានការគាំទ្រពីរដ្ឋាភិបាល គំរោងប្រើប្រាស់បង្គោលអង់តែនរួមគ្នាដែលនឹងលើកបង្ហាញនាថ្ងៃនេះនឹងជួយឱ្យរាជរដ្ឋាភិបាល និងបណ្ដាក្រុមហ៊ុនបំរើសេវាទូរគមនាគមន៍មានការយល់ដឹងអំពីតំរូវការនូវក្រុមហ៊ុនដែលមានលក្ខណៈសម្បត្តិ និងសមត្ថភាពប្រកួតប្រជែងគ្រប់គ្រាន់ស្របពេលជាមួយគ្នានោះ ក៏បានផ្សារភ្ជាប់គម្លាតក្នុងការទទួលបានសេវាទូរគមនាគមន៍ ព្រមទាំងពង្រឹងទស្សនាទាននៃការចែករំលែកបង្គោលអង់តែនប្រើប្រាស់រួមគ្នាផងដែរ ។ ហេតុដូច្នេះ ខ្ញុំសូមសដែងនូវការអំណរគុណចំពោះជំនាញការមកពីប្រទេសម៉ាឡេស៊ី ដែលនឹងឡើងថ្លែងបទបង្ហាញនាពេលបន្ទាប់នេះ ដើម្បីចែករំលែកព័ត៌មាន និងបទពិសោធន៍ទាក់ទិនទៅនឹងទស្សនាទាននេះ ។

**ឯកឧត្តម រដ្ឋមន្ត្រី ឯកឧត្តម លោកជំទាវ លោក លោកស្រី អ្នកនាងកញ្ញាជាទីគោរពរាប់អាន !**

ខ្ញុំសូមជំរាបជូន ឯកឧត្តម លោកជំទាវ អស់លោក លោកស្រីមេត្តាជ្រាបថា ទស្សនាទានចែករំលែកបង្គោលអង់តែនរួមគ្នានេះបានចាប់ផ្ដើមអនុវត្តន៍នៅក្នុងប្រទេសម៉ាឡេស៊ីចាប់តាំងពីឆ្នាំ ២០០១ មកម្ល៉េះ ។ ជាពិសេស ការចែករំលែកបង្គោលអង់តែនប្រើប្រាស់រួមគ្នានេះ នឹងជួយលើកកំពស់ការអភិវឌ្ឍន៍សេដ្ឋកិច្ចនិងលើកកំពស់គុណភាពជារួមនៃសេវាទូរគមនាគមន៍ ។

អត្ថប្រយោជន៍សំខាន់ៗជាចំបងនៃការរៀបចំការចែករំលែកនេះ រួមមានការកាត់បន្ថយនូវចំនួនបង្គោលអង់តែននៅទូទាំងប្រទេស និងជួយដល់ការកំណត់បានកាន់តែឆាប់រហ័សអំពីទីតាំងសមស្រប សំរាប់ធ្វើការដំឡើងបង្គោលអង់តែនថ្មីៗ ។ គំរោងនេះនឹងមិនគ្រាន់តែនាំឱ្យមានការប្រសើរឡើងក្នុងដំណើរការរបស់បណ្ដាញប៉ុណ្ណោះទេ ប៉ុន្តែវាក៏ធ្វើឱ្យដំណើរការដំឡើងបណ្ដាញទូរគមនាគមន៍អាចប្រព្រឹត្តទៅកាន់តែរលូន និងឆាប់រហ័សផងដែរ ដែលជាហេតុនាំឱ្យអាចសន្សំសំចៃការចំណាយបានកាន់តែច្រើនផងដែរ ។

ទស្សនាទានចែករំលែកការប្រើប្រាស់បង្គោលអង់តែនរួមគ្នាក៏អាចពង្រឹងសេដ្ឋកិច្ចក្នុងមូលដ្ឋាន បង្កើតប្រភពចំណូលដែលមានសក្ដានុពលសំរាប់ថវិកាថ្នាក់មូលដ្ឋាន និងអនុញ្ញាតឱ្យសហគមន៍អាចបញ្ជូនសេវាកម្មតាមរបៀបថ្មី ដែលមានប្រសិទ្ធភាព និងភាពច្នៃប្រឌិត ។

ទស្សនាទានប្រើប្រាស់បង្គោលអង់តែនរួមគ្នាកាន់តែលើកកំពស់ទំនុកចិត្តរបស់អតិថិជនបន្ថែមទៀតទៅលើសេវាកម្មទូរគមនាគមន៍ចល័ត និងបណ្តាក្រុមហ៊ុនបំរើសេវាកម្មដែលបានអនុវត្តន៍យ៉ាងខ្ជាប់ខ្ជួនតាមសេចក្តីណែនាំអំពីការបញ្ចេញប្រេកង់វិទ្យុ ដោយផ្អែកលើការអនុវត្តន៍ជាអន្តរជាតិល្អបំផុត ដូចដែលបានអនុវត្តន៍ដោយក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍។

**ឯកឧត្តម រដ្ឋមន្ត្រី ឯកឧត្តម លោកជំទាវ លោក លោកស្រី អ្នកនាងកញ្ញាជាទីគោរពរាប់អាន !**

សូមអនុញ្ញាតឱ្យខ្ញុំធ្វើការបញ្ជាក់បន្តិចបន្តួច អំពីការផ្តល់ជូននៅក្នុងន័យប្រសិទ្ធភាព ដែលការផ្តល់ជូននឹងត្រូវបានអនុវត្តន៍ដោយអ្នកជំនាញការពាក់ព័ន្ធដែលមានបទ- ពិសោធន៏រឹងមាំ និងទូលំទូលាយនៅក្នុងវិស័យនេះ។ លើសពីនេះទៀតនោះ ទស្សនាទានចែករំលែកបង្គោល អង់តែនរួមគ្នានេះត្រូវបានរៀបចំ និងសំរបទៅតាមក្របខណ្ឌត្រួតពិនិត្យ និងគោលនយោបាយប្រតិបត្តិការនិងនីតិវិធីផងដែរ។

យើងខ្ញុំគឺជាក្រុមហ៊ុនផ្តល់ហេដ្ឋារចនាសម្ព័ន្ធសេវាកម្មទូរគមនាគមន៍ ដែលមានជំនាញលើការគ្រប់គ្រង វិស្វកម្ម ការដំឡើង ការធ្វើតេស្តសាកល្បង និងសេវាពិគ្រោះយោបល់ទាក់ទិនទៅនឹង គំរោងដែលមានរចនាសម្ព័ន្ធធំៗ និងត្រូវការថប្រថុចញ៉ុច។ យើងផ្តល់ជូនក្រុមហ៊ុនទូរគមនាគមន៍ដែលមានបច្ចេកវិទ្យាខ្ពស់នូវសេវាកម្មប្រកបដោយតំលៃខ្ពស់ គុណភាពខ្ពស់ឆាប់រហ័ស និងអាចជឿទុកចិត្តបាន ដែលនេះជាជំរើសថ្មីមួយជំនួសធនធានខាងក្នុង។ ជំរើសថ្មីជំនួសធនធានខាងក្នុងនេះផ្តល់នូវបទពិសោធន៍ជាក់ស្តែង វិធីសាស្ត្រ ការទំនាក់ទំនង និងការរក្សាការសំងាត់ក្នុងកំរិតខ្ពស់មួយ។ អតិថិជនត្រូវជ្រាបថាការសហការជាមួយនឹង TMCC គឺជាវិធីសាស្ត្រមួយប្រកបដោយលក្ខណៈវិជ្ជាជីវៈកាន់តែខ្ពស់ និងមានការប្រថុយប្រថានកាន់តែតិចតួច ក្នុងការសំរេចឱ្យបាននូវការផ្តល់សេវាកម្មទាំងនេះ។ យើងខ្ញុំនឹងផ្តោតទៅលើការផ្តល់នូវសេវាកម្មប្រកបដោយឯកទេស ដើម្បីបំពេញតាមតំរូវការជាក់លាក់របស់អតិថិជន។

យើងខ្ញុំនឹងចាត់ទុកអតិថិជនរបស់យើងខ្ញុំថាជាមិត្តដែលអាចទុកចិត្តបាន ដោយផ្តល់ជូនពួកគេនូវភាពស្មោះត្រង់ក្នុងនាមជាដៃគូអាជីវកម្មមួយ។ យើងខ្ញុំត្រូវការដឹងថា អតិថិជនរបស់យើងខ្ញុំមានអ្វីៗដែលពួកគេត្រូវការសំរាប់ដំណើរការអាជីវកម្មរបស់ពួកគេឱ្យមានប្រសិទ្ធភាព និងប្រកបដោយលក្ខណៈអាចទុកចិត្តបានខ្ពស់បំផុត តាមដែលអាចធ្វើបាន។ យើងខ្ញុំនឹងធានាជូនដល់អតិថិជនរបស់យើងខ្ញុំថា យើងខ្ញុំនឹងនៅចាំជួយពួកគេជានិច្ច នៅពេលណាដែលពួកគេត្រូវការយើងខ្ញុំ។

ជាទីបញ្ចប់នេះ ខ្ញុំមានជំនឿយ៉ាងមុតមាំថា ដោយមានការសហការ ការចូលរួមយ៉ាងសកម្ម និងការគាំទ្រពីក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ក្រុមហ៊ុនបំរើសេវាទូរគមនាគមន៍ ក៏ដូចជាអ្នកជំនាញផ្នែកបច្ចេកវិទ្យានឹងទទួលបាននូវអត្ថប្រយោជន៍ពីការអនុវត្តន៍ប្រកបដោយជោគជ័យនៃទស្សនាទានចែករំលែកបង្គោលអង់តែនប្រើប្រាស់រួមគ្នានេះ ជាក់ជាពុំខាន។ ជាថ្មីម្តងទៀត ខ្ញុំសូមថ្លែងអំណរគុណចំពោះអង្គសិក្ខាសាលាទាំងមូល ជាពិសេស ជូនចំពោះគណៈប្រតិភូរបស់ប្រទេសម៉ាឡេស៊ី ដែលនឹងឡើងធ្វើបទបង្ហាញអំពីបទពិសោធន៍របស់ខ្លួននៅក្នុងអង្គសិក្ខាសាលានេះ ហើយនេះគឺជារឿងមួយដ៏សំខាន់និងមានតំលៃសំរាប់ប្រទេសកម្ពុជា ដែលទទួលបាននូវចំណេះដឹងទាំងនេះសំរាប់ប្រើប្រាស់ជាឧត្តមប្រយោជន៍ ក្នុងវិស័យទូរគមនាគមន៍ក្នុងប្រទេសទាំងមូល។

ឆ្លៀតក្នុងឱកាសនេះដែរ ខ្ញុំមានក្តីសង្ឃឹមថា អង្គសិក្ខាសាលានេះនឹងផ្តល់នូវសារប្រយោជន៍យ៉ាងច្រើន ចំពោះកិច្ចប្រឹងប្រែងរបស់យើងខ្ញុំ ក្នុងការកែលំអគុណភាពបណ្តាញទូរគមនាគមន៍នៅគ្រប់ទីកន្លែង។

អាស្រ័យហេតុនេះ សូមឯកឧត្តម លោកជំទាវ អស់លោក លោកស្រី ចូលរួមចំលែកពិភាក្សាឱ្យបានផុលផុស ដោយទទួលបានលទ្ធផលប្រកបដោយផ្លែផ្កានាឱកាសថ្ងៃនេះ។

សូមអរគុណជាថ្មីម្តងទៀតសំរាប់ការចូលរួមរបស់ឯកឧត្តមរដ្ឋមន្ត្រី ភ្ញៀវកិត្តិយស លោក លោកស្រី អ្នកនាង កញ្ញាទាំងអស់ ជាទីគោរពរាប់អាន!

## សុន្ទរកថាដ៏មានខ្លឹមសារ

## របស់រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍

## នៃព្រះរាជាណាចក្រកម្ពុជា [TMCC]

## ក្រោមប្រធានបទ

## សិក្ខាសាលាស្តីពីការប្រើប្រាស់បង្គោលអង់តែនរួម

សូមគោរពឯកឧត្តម លោកជំទាវលោក-លោកស្រីជាទីមេត្រី !

លោកនាយកចាត់ការក្រុមហ៊ុន TMCC អស់លោក-លោកស្រីជាអ្នកជំនាញការបច្ចេកទេស មន្ត្រីរដ្ឋាភិបាល ឯកឧត្តម លោកជំទាវ លោក-លោកស្រីជាអ្នកធ្វើបទបង្ហាញ សមាជិកក្រុមអ្នកសារព័ត៌មាន និងភ្ញៀវកិត្តិយស ទាំងឡាយ ។

ជំនួសមុខឱ្យក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍នៃព្រះរាជាណាចក្រកម្ពុជា ខ្ញុំមានកិត្តិយសណាស់ដែលបានចូលរួម ជាមួយលោក លោកស្រី ទាំងអស់គ្នានៅក្នុងសិក្ខាសាលាលើកកំពស់វិស័យទូរគមនាគមន៍ជាមួយនឹងទស្សនាទានការប្រើប្រាស់ បង្គោលអង់តែនរួមគ្នា។ ខ្ញុំសូមថ្លែងអំណរគុណចំពោះក្រុមហ៊ុន TMCC ដែលបានរៀបចំព្រឹត្តិការណ៍ដ៏សំខាន់នេះឡើង ។

បច្ចុប្បន្នមានសេវា ទូរគមនាគមន៍ដែលបំរើដោយក្រុមហ៊ុន Mobile Phone ចំនួន ៩ និង ISP/VOIP ជាច្រើនទៀត។ ចំនួនអតិថិជន ប្រមាណ ៥.៣ លាន ត្រូវការប្រើប្រាស់អង់តែនជាចំបាច់ចំពោះទូរសព្ទ័ចលត័ មាន Tower ចំនួនប្រហែល ៤៥00 ទាំងនៅដំបូល និង ផ្ទាល់ដី។

**ឯកឧត្តម លោកជំទាវ លោក-លោកស្រីជាទីមេត្រី !**

ដើម្បីធ្វើដំណើរការឱ្យទាន់ពេលវេលានឹងការរីកចំរើនយ៉ាងឆាប់រហ័សនៃវិស័យទូរគមនាគមន៍នៅលើសកលលោកនោះ ដែលមានការផ្លាស់ប្តូរជាច្រើនត្រូវបានធ្វើឡើងដើម្បីបំពេញទៅតាមតំរូវការជាសកលដែលកំពុងកើនឡើងនេះ។ ហេតុដូច្នេះ វិស័យនេះចាំបាច់ត្រូវមានការត្រៀមបំរុង ដើម្បីឆ្លើយតបចំពោះការផ្លាស់ប្តូរទាំងនេះឱ្យស្របទៅតាមការវិវឌ្ឍន៍នៃបច្ចេកវិទ្យានៅលើសកលលោក។ ក្នុងចំណោមទស្សនាទានថ្មីៗដែលត្រូវបានបង្កើតឡើង និងអនុវត្តនៅទូរទាំង សកលលោកនោះ រួមមានការ អភិវឌ្ឍន៍ផ្នែកហេដ្ឋារចនាសម្ព័ន្ធទូរគមនាគមន៍នៅក្នុងទំរង់ជាការប្រើប្រាស់បង្គោលអង់តែន រួមដែរ។ ហេតុដូច្នេះយើងត្រូវតែមានការប្រុងប្រយ័ត្ន និង ឆ្លើយតបឱ្យបានឆាប់រហ័សទៅនឹងរាល់ទិដ្ឋភាពទាំងអស់នៃការ រៀបចំផែនការអាជីវកម្ម ការរៀបចំ រចនាសម្ព័ន្ធហិរញ្ញវត្ថុ និង ការអនុវត្តន៍ហេដ្ឋារចនាសម្ព័ន្ធបណ្តាញ។

យើងទទួលស្គាល់ថា ទីផ្សារទូរគមនាគមន៍ដែលកំពុងផ្លាស់ប្តូរយ៉ាងឆាប់រហ័សនោះបាននាំឱ្យមានបញ្ហាប្រឈមផ្នែក អាជីវកម្ម និង ផ្លូវច្បាប់ថ្មីៗដែលទាមទារឱ្យមានដំណោះស្រាយពហុឯកទេស។ លើសពីនេះទៀតតាមរយៈការអនុវត្តន៍ជា លក្ខណៈអន្តរជាតិ និង ដោយស្របច្បាប់របស់យើងធ្វើឱ្យយើងអាចប្រមើលមើលទៅថ្ងៃខាងមុខអំពីវិស័យទូរគមនាគមន៍ ដែលកំពុងរីកចំរើនជាមួយនឹងបច្ចេកវិទ្យាថ្មី ដែលជាពិសេសពាក់ព័ន្ធទៅនឹងទស្សនាទាននៃការប្រើប្រាស់បង្គោលអង់តែនរួម។

ដើម្បីឆ្លើយតបនឹងការនេះ ខ្ញុំសង្ឃឹមថា រាល់បណ្តាក្រុមហ៊ុនផ្តល់សេវាកម្មទូរគមនាគមន៍ទាំងអស់នឹងរួមគ្នាអនុវត្ត នូវដំណោះ ស្រាយមួយ ដែលកាន់តែមានលក្ខណៈជាយុទ្ធសាស្ត្រដើម្បីលើកកំពស់សេវាកម្មបណ្តាញរបស់ខ្លួន។ នៅក្នុងកិច្ច ខិតខំប្រឹងប្រែង ដើម្បីកាន់តែទទួលបានជោគជ័យក្នុងការធ្វើឱ្យអតិថិជនពេញចិត្តនោះ ក្រុមហ៊ុន

TMCC កំពុងពិចារណា ថ្លឹងថ្លែងលើការ វិនិយោគ បច្ចេកវិទ្យារបស់ខ្លួនទៅលើអាជីវកម្មជាក់លាក់មួយ ដែលទាក់ទិនទៅនឹងការប្រើប្រាស់បង្គោល អង់តែនរួម ដើម្បី បំរើដល់ការអភិវឌ្ឍន៍នៃវិស័យទូរគមនាគមន៍។

ជាពិសេសទៅទៀតនោះ ទីផ្សារទូរគមនាគមន៍នាពេលបច្ចុប្បន្នកំពុងប្រឈមនឹងការប្រកួតប្រជែងដ៏តឹងតែង ដោយបណ្តាក្រុមហ៊ុននានា កំពុងតែខិតខំប្រឹងប្រែងការពារ និង ពង្រឹងមូលដ្ឋានអតិថិជនដែលមានស្រាប់របស់ពួកគេរៀង១ ខ្លួន ហើយ ស្របពេលជាមួយគ្នានោះ ក្រុមហ៊ុនទាំងនោះក៏កំពុងខិតខំពង្រីកបន្ថែមនូវសេវាកម្មថ្មីបន្តបន្ថែមទៀតយ៉ាងក្លៀវក្លា។ ហេតុ ដូច្នេះ តាមរយៈទស្សនាទានប្រើប្រាស់បង្គោលអង់តែនរួមដែលក្រុមហ៊ុន TMCC បានណែនាំនេះ បណ្តាក្រុមហ៊ុនបំរើ សេវាកម្មទូរគមនាគមន៍ទាំងអស់អាចរីករាយនឹងការទទួលបានអត្ថប្រយោជន៍ជាវិជ្ជមានផងដែរ។ ស្របពេលជាមួយគ្នានេះ ក្រុមហ៊ុនទាំងនោះក៏អាចផ្តោតការយកចិត្តទុកដាក់ទៅលើការកាត់បន្ថយឱ្យបានជាអប្បបរិមានូវថ្លៃដើមពង្រាយហេដ្ឋារចនាសម្ព័ន្ធបណ្តាញ និងថ្លៃដើមផ្សេង១ទៀត។ នេះគឺជាផ្នែកមួយនៃគំនិតផ្តួចផ្តើមរបស់រាជរដ្ឋាភិបាលក្នុង ការលើកកំពស់សេវាកម្ម បណ្តាញប្រកបដោយប្រសិទ្ធភាព ដែលនឹងបង្កើនគុណភាពការងារ និងគុណភាពជីវិត ព្រមទាំងដើម្បីធានាបានការ កាត់បន្ថយការចំណាយលើដើមទុនបានល្អ។

**ឯកឧត្តម លោកជំទាវ លោក-លោកស្រីជាទីមេត្រី !**

ក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍បានទទួលសំណើពីក្រុមហ៊ុន TMCC ក្នុងការអនុវត្តន៍គំរោងប្រើប្រាស់បង្គោលអង់តែនរួមគ្នានេះ។ យើងកំពុងសិក្សាយ៉ាងយកចិត្តទុកដាក់លើសំណើទាំងនេះទាក់ទិននឹងសមត្ថភាពបច្ចេកវិទ្យា និង ផលប៉ះ ពាល់ទៅលើកំណើនសេដ្ឋកិច្ចនៅក្នុងអាជីវកម្មទូរគមនាគមន៍។ តាមរយៈការផ្សព្វផ្សាយទស្សនាទានដែលត្រូវបានអនុវត្តន៍រួចមកហើយ ជាពិសេសនៅក្នុងប្រទេសម៉ាឡេស៊ីនោះ ក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍មានទំនុកចិត្តថា គំរោងនេះអាច ជំរុញការអភិវឌ្ឍន៍នៃសេវាកម្មទូរគមនាគមន៍ដើម្បីបំពេញតាមតំរូវការ និង ការចង់បានរបស់ក្រុមហ៊ុន ផ្តល់សេវាកម្ម ក្នុងស្រុក។

ជាថ្មីម្តងទៀត ខ្ញុំសូមធ្វើការបញ្ជាក់ថា កម្មវិធីប្រើប្រាស់បង្គោលអង់តែនរួមនោះ នឹងទទួលបានអាទិភាពស្របតាម គោលនយោបាយជាតិរបស់យើង ដើម្បីឈានទៅការអនុវត្តន៍ដែលមានលក្ខណៈជាអន្តរជាតិជាជំហាន១ ជាពិសេសសំរាប់ប្រទេសកំពុងអភិវឌ្ឍន៍ ដូចជាប្រទេសកម្ពុជាជាដើម ។

ក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍នឹងផ្តល់កិច្ចសហប្រតិបត្តិការជាមួយស្ថាប័នពាក់ព័ន្ធទាំងអស់ដើម្បីរៀបចំ ផែនគំរោង អនុវត្តន៍បង្គោលអង់តែននេះ ប្រកបដោយលក្ខណៈស៊ីជំរៅព្រមទាំងបង្កើតការគាំទ្រខ្លាំងក្លាពីទីភ្នាក់ងាររដ្ឋាភិ- បាលក្នុងមូលដ្ឋាន ដូចជា ស្ថាប័នអាជ្ញាធរក្នុងមូលដ្ឋានជាដើម ។

**ឯកឧត្តម លោកជំទាវ លោក-លោកស្រីជាទីមេត្រី !**

ការរៀបចំហេដ្ឋារចនាសម្ព័ន្ធបង្គោលអង់តែនសំរាប់បំរើបច្ចេកទេស microwave នេះ ក្រសួងបានមានផែនការជាចក្ខុវិស័យជាយូរឆ្នាំមកហើយ តែពុំមានលទ្ធភាពនឹងបំពេញបាន ម្ល៉ោះហើយក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ត្រូវតែអនុញ្ញាតិឱ្យបណ្តាប្រតិបត្តិករ ទូរគមនាគមន៍ទាំងអស់ដោះស្រាយហើយម្ចាស់ការជាបណ្តោះអាសន្នសិន ទម្រាំនឹងមានលទ្ធភាពរៀបចំបណ្តាញជារួមមួយបាន ។

ដូចនេះពេលនេះ ខ្ញុំមានសេចក្តីសោមនស្សរីករាយដែលបានស្វាគមន៍គណៈប្រតិភូមកពីប្រទេសម៉ាឡេស៊ីដែលនឹងផ្តល់នូវបទបង្ហាញដើម្បីចែករំលែកបទពិសោធន៍ និង ជំនាញរបស់ពួកគេក្នុងការអភិវឌ្ឍន៍នូវទស្សនាទានចែក រំលែកហេដ្ឋារចនា សម្ព័ន្ធនេះ ។

**ជាមួយគ្នានេះ ខ្ញុំសូមបើកសិក្ខាសាលានេះជាផ្លូវការ ។**

**សូមអរគុណ**

# សុន្ទរកថាបិទកម្មវិធីសិក្ខាសាលា

# ស្តីពី

# ការប្រើប្រាស់បង្គោលអង់តែនរួម

សូមគោរពឯកឧត្តមរដ្ឋមន្ត្រី ភ្ញៀវកិត្តិយស លោក-លោកស្រីជាវាគ្មិន ជំនាញការ សិក្ខាកាម លោក-លោកស្រីទាំងអស់ ជាទីគោរពរាប់អាន!

ជាបឋមនេះ ខ្ញុំបាទសូមថ្លែងនូវអំណរគុណយ៉ាងជ្រាលជ្រៅជូនចំពោះ ឯកឧត្តម លោក-លោកស្រី ជាវាគ្មិន និងសិក្ខាកាមទាំងអស់ ដែលអញ្ជើញមានវត្តមានយ៉ាងផុលផុសនៅក្នុងអង្គសិក្ខាសាលាដែលប្រារព្ធឡើងនាថ្ងៃនេះ។

ខ្ញុំបាទមានក្តីសោមនស្សរីករាយជាពន់ពេក ដែលមានកិត្តិយសឡើងថ្លែងសុន្ទរកថាបិទនៅក្នុងពិធីដ៏ឧឡារិកនេះ ដើម្បីចូលរួមចែករំលែកនូវទស្សនាទានជុំវិញការប្រើប្រាស់កបង្គោលអង់តែនរួមគ្នា នៅក្នុងអង្គសិក្ខាសាលានេះ។ នេះគឺជាសិក្ខាសាលាលើកទីមួយហើយ ដែលរៀបចំឡើង ស្តីពីការជំរុញ និងលើកកំពស់នូវទស្សនាទានប្រើប្រាស់បង្គោលអង់តែនរួមគ្នានៅក្នុងព្រះរាជាណាចក្រកម្ពុជា។ ជាការពិតណាស់ តាមរយៈបទពិសោធន៍ និងភាពជោគជ័យនានាដែលវាគ្មិនទាំងអស់សំរេចបានលើផ្នែកនីមួយៗ គឺសុទ្ធសឹងជាកត្តារួមចំណែកធ្វើឱ្យអង្គសិក្ខាសាលានេះអាចប្រព្រឹត្តទៅប្រកបទៅដោយជោគជ័យ។

ដូចដែលឯកឧត្តម លោកជំទាវ អស់លោក-លោកស្រីបានជ្រាបស្រាប់ហើយថា វិស័យទូរគមនាគមន៍នៅក្នុងប្រទេសកម្ពុជា គឺជាវិស័យថ្មីមួយដែលកំពុងតែមានការអភិវឌ្ឍរីកចំរើន។ ការងារជាអាទិភាពរបស់យើង គឺធ្វើយ៉ាងណាជំរុញឱ្យការងារទាំងឡាយអាចដំណើរការទៅយ៉ាងឆាប់រហ័ស និងប្រកបដោយប្រសិទ្ធភាព។ ទន្ទឹមនឹងនេះដែរ ដើម្បីធានាសំរេចបាននូវជោគជ័យនៅឆ្នាំដំបូង បន្ទុកការងារជាច្រើន នឹងត្រូវធ្លាក់មកលើអ្នកសង្កេតការណ៍នៅតាមបណ្តាខេត្តនានា។

ដូចដែលមានកត់សំគាល់នៅក្នុងសុន្ទរកថាបើករបស់ឯកឧត្តម**សូរ ឃុន** រួចមកហើយថា គំនិតផ្តួចផ្តើមរបស់ក្រុមហ៊ុន TMCC និងក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ មានចំណុចសំខាន់ថ្មីៗមួយចំនួន។ គោលដៅសំខាន់នៃការចែករំលែកបង្គោលអង់តែនប្រើប្រាស់រួមគ្នាគឺធ្វើយ៉ាងណាឱ្យទទួលបាននូវលទ្ធផលសំខាន់ៗ ជាជាងផ្តោតការយកចិត្តទុកដាក់តែលើសកម្មភាពនៃកម្មវិធីនេះ។

ជាថ្មីម្តងទៀត ខ្ញុំបាទសូមធ្វើការបង្ហាញអំពីលទ្ធផលសំខាន់ៗមួយចំនួនដែលយើងនឹងទទួលបានពីកម្មវិធីនេះ។ គោលបំណងចំបងរបស់វា គឺការចាប់ផ្តើមកាត់បន្ថយចំនួនបង្គោលអង់តែនទាំងអស់ដែលមាននៅក្នុងប្រទេសកម្ពុជា ដែលជាលទ្ធផល ការចំណាយទុន និងចំណាយប្រតិបត្តិការនឹងអាចកាត់បន្ថយបានយ៉ាងច្រើន។ ក្រសួងចាត់ទុកថា នេះគឺជាសមិទ្ធផលមួយ ដែលនឹងសំរេចឡើង តាមរយៈជំនាញឯកទេស និងបទពិសោធន៍នានា ជាពិសេសនៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍។ ក្នុងន័យនេះ រាជរដ្ឋាភិបាលនៃប្រទេសកម្ពុជាបានសំរេចដាក់ចេញនូវទស្សនាទាននេះ សំរាប់អនុវត្តចំពោះបណ្តាក្រុមហ៊ុនបំរើសេវាកម្មទូរគមនាគមន៍ទាំងអស់ នៅក្នុងប្រទេសកម្ពុជា។

លើសពីនេះទៀតនោះ អង្គសិក្ខាសាលានាថ្ងៃនេះ ក៏មានគោលបំណងធ្វើការពន្យល់ណែនាំអំពីទស្សនាទាននេះ ដែលជាការជួយជំរុញលើកកំពស់វិស័យទូរគមនាគមន៍ប្រកបដោយគុណភាព និងគាំទ្រដល់ការអនុវត្តន៍ដ៏ជោគជ័យជាលក្ខណៈអន្តរជាតិ។ តាមរយៈនេះ យើងនឹងមានលទ្ធភាពអាចលើកកំពស់ទាំងគុណភាព និងប្រសិទ្ធភាពនៃសេវាកម្មទូរគមនាគមន៍។

ឆ្លៀតក្នុងឱកាសនេះដែរ ខ្ញុំបាទសូមលើកឡើងអំពីសារៈសំខាន់នៃការទទួលខុសត្រូវ និងតម្លាភាពនៅក្នុងកម្មវិធីនេះ។ គោលដៅសំខាន់នៃទស្សនាទានចែករំលែកបង្គោលអង់តែនប្រើប្រាស់រួមគ្នា គឺការធានាឱ្យបាននូវការចំណាយថវិកាដោយត្រឹមត្រូវ និងប្រកបដោយគណនេយ្យភាព។ យើងសង្ឃឹមថា ក្នុងនាមជាអ្នកផ្តល់រចនាសម្ព័ន្ធទាំងនេះ ក្រុមហ៊ុន TMCC នឹងចូលរួមចំណែកក្នុងការគ្រប់គ្រងកម្មវិធីនេះប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់បំផុត។ ជាពិសេស ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ នឹងឃ្លាំមើលការអនុវត្តកិច្ចខិតខំប្រឹងប្រែងទាំងនេះយ៉ាងយកចិត្តទុកដាក់ ដែលជាផ្នែកមួយនៃកិច្ចព្រមព្រៀង។

ជាមួយគ្នានេះដែរ ខ្ញុំបាទសូមធ្វើការឆ្លុះបញ្ចាំងអំពីសារៈសំខាន់នៃកម្មវិធីចែករំលែកបង្គោលអង់តែនប្រើប្រាស់រួមគ្នា និងការប្រើប្រាស់ហេដ្ឋារចនាសម្ព័ន្ធទូរគមនាគមន៍តាមបែបវិមជ្ឈការជារួម។ កម្មវិធីនេះនឹងត្រូវពង្រីកនៅទូទាំងផ្ទៃប្រទេសជាមួយនឹងភាពជោគជ័យនៃការអនុវត្តជាក់ស្តែង។ ទន្ទឹមនឹងការបែងចែកការទទួលខុសត្រូវនៅទូទាំងវិស័យទូរគមនាគមន៍នៅក្នុងប្រទេសនេះ យើងពិតជាត្រូវការទាំងការគាំទ្រ និងការចូលរួមពីគ្រប់បណ្តាក្រុមហ៊ុនបំរើសេវាកម្មទូរគមនាគមន៍ទាំងអស់នៅក្នុងប្រទេសកម្ពុជា។ ការបង្កើតនូវកម្មវិធីថ្មីនេះ គឺជាជំហានមួយនៃការអភិវឌ្ឍន៏វិស័យទូរគមនាគមន៍ នៅក្នុងប្រទេសនេះ។

**ឯកឧត្តមរដ្ឋមន្ត្រី ភ្ញៀវកិត្តិយស លោក-លោកស្រីទាំងអស់ ជាទីគោរព !**

ដូចដែលបានជំរាបជូនខាងដើម យើងឃើញថា គំរោងនេះពិតជាធាតុមួយដ៏សំខាន់ ហើយ គំរោងនេះនឹងត្រូវដាក់ឱ្យដំណើរអនុវត្តនីសាកល្បងនៅក្នុងព្រះរាជាណាចក្រកម្ពុជា។ ការអនុវត្តនីកម្មវិធីនេះ នឹងផ្តល់ជាគំរូមួយដែលនឹងឆ្លុះបញ្ចាំងនូវទស្សនាទាននេះ។

ក្នុងន័យនេះ ខ្ញុំបាទសូមសំណូមពរជូនចំពោះឯកឧត្តម ភ្ញៀវកិត្តិយស លោក លោកស្រី ទាំងអស់ សូមមានស្មារតីទទួលខុសត្រូវខ្ពស់ ក្នុងការរៀបចំឱ្យមានប្រព័ន្ធរាយការណ៍បច្ចេកទេសដ៏ត្រឹមត្រូវ។ អ្វីដែលយើងត្រូវការនោះ គឺ ការរាយការណ៍មួយដែលទាន់ពេលវេលា នៅគ្រប់កំរិតនៃដំណើរការទាំងអស់។ ទន្ទឹមនឹងនេះ យើងខ្ញុំសង្ឃឹមផងដែរថា នឹងមានការបណ្តុះបណ្តាលបន្ថែមដល់ក្រុមហ៊ុនបំរើសេវាកម្មទូរគមនាគមន៍ ដើម្បីឱ្យបានយល់អំពីរបៀបនៃការរាយការណ៍ព័ត៌មានប្រកបដោយប្រសិទ្ធភាព។ ខ្ញុំបាទសង្ឃឹមថា ទស្សនាទានទាំងអស់របស់គំរោងនឹងត្រូវរៀបចំឡើងយ៉ាងល្អត្រឹមត្រូវ។ ដំណើរការទាំងនេះ មានបំណងឆ្លុះបញ្ចាំងពីសារៈសំខាន់នៃការទទួលខុសត្រូវទៅវិញទៅមក ដើម្បីធានាឱ្យបាននូវការអនុវត្តប្រកបដោយជោគជ័យនូវទស្សនាទាននៃការចែករំលែកបង្គោលអង់តែនប្រើប្រាស់រួមគ្នា។

ជាទីបញ្ចប់នេះ ខ្ញុំបាទសង្ឃឹមថា តាមរយៈបទពិសោធន៍របស់ប្រទេសម៉ាឡេស៊ី នឹងផ្តល់ជាបទដ្ឋាន និងមគ្គុទ្ទេសក៏មួយ សំរាប់ជាគន្លឹះក្នុងការអនុវត្តនីទស្សនាទានចែករំលែកបង្គោលអង់តែនប្រើប្រាស់រួមគ្នា នៅក្នុងប្រទេសរបស់យើង។ បទពិសោធន៍ដែលទទួលបានពីការទស្សនាទានចែករំលែកបង្គោលអង់តែនប្រើប្រាស់រួមគ្នា នឹងចូលរួមចំណែកដល់ការកាត់បន្ថយនូវហានិភ័យក្នុងការវិនិយោគសំរាប់បណ្តាប្រតិបត្តិករ ព្រមទាំង ជំរុញការប្រើប្រាស់ទុនវិនិយោគកាន់តែមានប្រសិទ្ធភាព ដែលជាលទ្ធផល ធ្វើឱ្យសំរេចបានតាមគោលដៅនៃការផ្តល់សេវាគ្របដណ្តប់ជាសកល។

ឆ្លៀតក្នុងឱកាសនេះដែរ ខ្ញុំបាទសូមថ្លែងអំណរគុណជូនចំពោះ ឯកឧត្តម រដ្ឋមន្ត្រី លោក លោកស្រី និងភ្ញៀវកិត្តិយសទាំងអស់ ដែលបានឆ្លៀតឱកាសដ៏មានតំលៃមកចូលរួមក្នុងកម្មវិធីនេះជាមួយនឹងយើងខ្ញុំ។

ជាបន្តនេះ ខ្ញុំបាទសូមប្រកាសបិទសិក្ខាសាលានេះជាផ្លូវការត្រឹមនេះ។

សូមអរគុណ!